សកម្មភាពទី ១

# ការមានភាពម៉ឺងម៉ាត់

សូមអាន មរមន ១:២, ១៥ ហើយពិចារណាគូសចំណាំពាក្យ « ដ៏ម៉ឺងម៉ាត់ » ។ ( អ្នកអាចនឹងកត់ត្រានៅក្នុងបទគម្ពីររបស់អ្នកថា ដ៏ម៉ឺងម៉ាត់ អាចមានន័យថា គារវភាព ម៉ត់ចត់ និងចេះគិតវែងឆ្ងាយ ) ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ប៊ុយដ៍ ខេ ផាកកឺ ( ឆ្នាំ ១៩២៤–ឆ្នាំ ២០១៥ ) ក្នុងក្លូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



យើងបានមើលឃើញលំនាំនៃគារវភាព និងការមិនមានគារវភាពនៅក្នុងសាសនាចក្រ ។ ខណៈពេលដែលមនុស្សជាច្រើនកំពុងតែមានគេសរសើរយ៉ាងខ្លាំង យើងក៏កំពុងត្រូវបានផាត់ចេញទៅដែរ ។ យើងមានហេតុផលដែលត្រូវឲ្យយើងមានការព្រួយបារម្ភជាខ្លាំង ។ . . .

ការគ្មានគារវភាពគឺត្រូវនឹងគោលបំណងរបស់មារសត្រូវ ដោយរារាំងផ្លូវដ៏ពិសេសនៃវិវរណៈទាំងក្នុងគំនិត និងវិញ្ញាណ ។ ( ប៊ុយដ៍ ខេ ផាកកឺ « Reverence Invites Revelation » Ensign ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ២២ )

- តើមានអ្វីខ្លះដែលគួរមានគារវភាព និងម៉ឺងម៉ាត់ ប៉ុន្តែអ្នកខ្លះមិនប្រព្រឹត្តបែបដូច្នេះទេ ?
- តើរបៀបណាខ្លះដែលព្រះអង្គសង្គ្រោះធ្វើជាគំរូអំពីការមានភាពម៉ឺងម៉ាត់ ( គារវភាព ម៉ត់ចត់ និងចេះគិតគូរវែងឆ្ងាយ ) ?

សកម្មភាពទី ២

# ចេះសង្កេតដោយឆាប់រហ័ស

សូមអាន មរមន ១:២ ហើយពិចារណាគូសចំណាំឃ្លា « ចេះសង្កេតដោយឆាប់រហ័ស » ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



នៅពេលដែលយើងចេះសង្កេតដោយឆាប់រហ័ស យើងក្រឡេកមើល ឬកត់សម្គាល់ និងគោរពតាមបានយ៉ាងលឿន ។ ធាតុដែលជាមូលដ្ឋានគ្រឹះទាំងពីរនេះ—ការមើលទៅ និងការគោរពប្រតិបត្តិ—គឺមានសារៈសំខាន់ណាស់ក្នុងការចេះសង្កេតដោយឆាប់រហ័ស ។ ហើយព្យាការីមរមន គឺជាគំរូដ៏គួរឲ្យចាប់អារម្មណ៍នៃអំណោយទាននេះនៅក្នុងការអនុវត្តបែបនេះ ។ ( ដាវីឌ អេ បែដណា « Quick to Observe » Ensign ខែ ធ្នូ ឆ្នាំ ២០០៦ ទំព័រ ៣២ )

- តើការបង្រៀនអ្វីខ្លះដែលអ្នកបានរកឃើញថា វាមានប្រយោជន៍ក្នុងការកត់សម្គាល់ និងគោរពតាមដោយឆាប់រហ័ស ? ហេតុអ្វី ?
- តើមានដំបូន្មានអ្វីខ្លះដែលអ្នកនឹងផ្ដល់ទៅដល់មិត្តម្នាក់ដែលគិតថា ការគោរពប្រតិបត្តិព្រះអម្ចាស់អាចចាំដល់រហូតពេលដែលមានវ័យចំណាស់ ។
- តើព្រះយេស៊ូវគ្រីស្ទបានធ្វើជាគំរូចំពោះការចេះសង្កេតដោយឆាប់រហ័សតាមរបៀបណាខ្លះ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved.
PD60013873_258_441-teacher_handout-1
PD60013873_258_441-teacher_handout-2